**STATE OF CALIFORNIA - HEALTH AND HUMAN SERVICES AGENCY CALIFORNIA DEPARTMENT OF SOCIAL SERVICES**

# កម្មវិធីសេវាគាំពារនៅផ្ទះ (IHSS)
# ផ្នែកផ្សេងៗក្នុងក្រមរបស់រដ្ឋ CALIFORNIA

**Section 273a នៃក្រមព្រហ្មទណ្ឌនៃរដ្ឋ California កថាខណ្ឌ** (a)

(a) ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារខោនធី មិនលើសពីមួយឆ្នាំ ឬក្នុងពន្ធនាគាររដ្ឋ មិនលើសពីពីរ បួន ឬប្រាំមួយឆ្នាំ ចំពោះជនណា ដែលដោយស្ថិតក្រោមកាលៈទេសៈ ឬស្ថានភាពអាចបង្កគ្រោះថ្នាក់ដល់រូបកាយធ្ងន់ធ្ងរ ឬអាយុជីវិត មានចេតនាបណ្តាលឲ្យ ឬអនុញ្ញាតឲ្យកុមារណាម្នាក់ទទួលរងទុក្ខ ឬធ្វើឲ្យឈឺចាប់រូបកាយ ឬផ្លូវចិត្តដោយគ្មានហេតុផល ឬដោយទទួលបន្ទុកថែទាំ ឬឃុំគ្រងកុមារ មានចេតនាបណ្តាលឱ្យ ឬអនុញ្ញាតឱ្យរូបកាយ ឬសុខភាពរបស់កុមាររងរបួស ឬមានចេតនាបណ្តាលឲ្យ ឬអនុញ្ញាតឲ្យកុមារស្ថិតក្នុងស្ថានភាព ដែលរូបកាយ ឬសុខភាពរបស់គេ ស្ថិតក្នុងគ្រោះថ្នាក់ ។

**Section 368 នៃក្រមព្រហ្មទណ្ឌរដ្ឋ California**

(a) អង្គនីតិប្បញ្ញត្តិរកឃើញ និងប្រកាសថា ឧក្រិដ្ឋកម្មប្រឆាំងនឹងចាស់ជរា និងមនុស្សពេញវ័យក្នុងបន្ទុក សមនឹងទទួលបាននូវការពិចារណា និងកិច្ចការពារជាពិសេស មិនដូចកិច្ចការពារពិសេស ដែលបានផ្តល់ជូនកុមារអនីតិជនទេ ព្រោះថា ចាស់ជរា និងមនុស្សពេញវ័យអាចមានការភ័ន្តច្រឡំដោយសារថ្នាំផ្សេងៗ ដោយសារមានបញ្ហាផ្លូវចិត្ត ឬរូបកាយ ឬដោយសារអសមត្ថភាព ដូច្នេះ មិនមានលទ្ធភាពការពារខ្លួនឯងបានទេ យល់ដឹងពី ឬរាយការណ៍ពីសកម្មភាពល្មើសច្បាប់ទេ ឬក៏ផ្តល់ចម្លើយ ក្នុងនីតិវិធីតុលាការ ដោយខ្លួនឯង។

(b) (1) ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារខោនធី មិនលើសពីមួយឆ្នាំ ឬពិន័យជាប្រាក់មិនលើសពីប្រាំមួយពាន់ដុល្លារ ($6,000) ឬត្រូវជាប់ពន្ធនាគាររដ្ឋ មិនលើសពីពីរ បី ឬបួនឆ្នាំ ចំពោះជនណា ដែលស្គាល់ ឬគួរស្គាល់ថា បុគ្គលជាចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក និងដែលដោយស្ថិតក្រោមកាលៈទេសៈ ឬស្ថានភាពអាចបង្កគ្រោះថ្នាក់ដល់រូបកាយធ្ងន់ធ្ងរ ឬអាយុជីវិត មានចេតនាបណ្តាលឲ្យឬអនុញ្ញាតឲ្យចាស់ជរា ឬមនុស្សពេញវ័យណាម្នាក់ទទួលរងទុក្ខ ឬធ្វើឲ្យឈឺចាប់រូបកាយ ឬផ្លូវចិត្តដោយគ្មានហេតុផល ឬដោយទទួលបន្ទុកថែទាំ ឬឃុំគ្រងចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក មានចេតនាបណ្តាលឱ្យ ឬអនុញ្ញាតឱ្យរូបកាយ ឬសុខភាពរបស់ចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុករងរបួស ឬមានចេតនា បណ្តាលឲ្យ ឬអនុញ្ញាតឲ្យចាស់ជរា ឬមនុស្សពេញវ័យស្ថិតក្នុងស្ថានភាព ដែលរូបកាយ ឬសុខភាពរបស់គេ ស្ថិតក្នុងគ្រោះថ្នាក់ ។
(2) ប្រសិនបើក្នុងពេលប្រព្រឹត្តបទល្មើស ដូចចែងក្នុងកថាខណ្ឌ (1) ជនរងគ្រោះរងរបួសរូបកាយធ្ងន់ធ្ងរ តាមនិយមន័យក្នុង Section 12022.7 ជនជាប់ចោទត្រូវទទួលទោសជាប់ពន្ធនាគារបន្ថែម ដូចខាងក្រោម៖
(A) រយៈពេលបីឆ្នាំ ប្រសិនបើជនរងគ្រោះ មានអាយុក្រោម 70 ឆ្នាំ។
(B) រយៈពេលប្រាំឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុ 70 ឆ្នាំ ឬលើសនេះ។
(3) ប្រសិនបើក្នុងពេលប្រព្រឹត្តបទល្មើស ដូចចែងក្នុងកថាខណ្ឌ (1) ជនជាប់ចោទស្ទើរតែបណ្តាលឲ្យជនរងគ្រោះស្លាប់បាត់បង់ជីវិត ជនជាប់ចោទនឹងត្រូវទទួលទោសជាប់ពន្ធនាគារបន្ថែម ដូចខាងក្រោម៖
(A) រយៈពេលប្រាំឆ្នាំ ប្រសិនបើជនរងគ្រោះ មានអាយុក្រោម 70 ឆ្នាំ។
(B) រយៈពេលប្រាំពីរឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុ 70 ឆ្នាំ ឬលើសនេះ។

(c) ត្រូវមានពិរុទ្ធភាពពីបទមជ្ឈឹម ចំពោះជនណា ដែលស្គាល់ ឬគួរស្គាល់ថា បុគ្គលជាចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក ហើយដែលដោយស្ថិតក្រោមកាលៈទេសៈ ឬស្ថានភាពផ្សេង ក្រៅពីកាលៈទេសៈ ឬស្ថានភាពអាចបង្កគ្រោះថ្នាក់ដល់រូបកាយធ្ងន់ធ្ងរ ឬអាយុជីវិត មានចេតនាបណ្តាលឲ្យ ឬអនុញ្ញាតឲ្យចាស់ជរា ឬមនុស្សពេញវ័យណាម្នាក់ទទួលរងទុក្ខ ឬធ្វើឲ្យឈឺចាប់រូបកាយ ឬផ្លូវចិត្តដោយគ្មានហេតុផល ឬដោយទទួលបន្ទុកថែទាំ ឬឃុំគ្រងចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក មានចេតនាបណ្តាលឱ្យ ឬអនុញ្ញាតឱ្យរូបកាយ ឬសុខភាពរបស់ចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក រងរបួស ឬមានចេតនាបណ្តាលឲ្យ ឬអនុញ្ញាតឲ្យចាស់ជរា ឬមនុស្សពេញវ័យស្ថិតក្នុងស្ថានភាព ដែលរូបកាយ ឬសុខភាពរបស់គេ អាចស្ថិតក្នុងគ្រោះថ្នាក់។ ការរំលោភបំពានលើមាត្រានេះលើកទីពីរ ឬជាបន្ទបន្ទាប់ នឹងត្រូវពិន័យជាប្រាក់ មិនលើសពីពីរពាន់ដុល្លារ ($2,000) ឬផ្តន្ទាទោសឲ្យជាប់ក្នុងពន្ធនាគារខោនធីមិនលើសពីមួយឆ្នាំ ឬទាំងពិន័យផង និងទោសជាប់ពន្ធនាគារផង។

(d) ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីមិនលើសពីមួយឆ្នាំ ឬពន្ធនាគាររដ្ឋរយៈពេលពីរ បី ឬបួនឆ្នាំ នៅពេលប្រាក់ កម្លាំងពលកម្ម ទំនិញ សេវាកម្ម ឬចលនទ្រព្យ ឬអចលនទ្រព្យ ដែលទទួលយក ឬទទួលបាន មានតម្លៃលើសពីបួនរយដុល្លារ ($400) និងត្រូវពិន័យជាប្រាក់មិនលើសពីមួយពាន់ដុល្លារ ($1,000) ឬផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីមិនលើសពីមួយឆ្នាំ ឬទាំងពិន័យផង និងទាំងទោសជាប់ពន្ធនាគារផង នៅពេលប្រាក់ កម្លាំងពលកម្ម ទំនិញ សេវាកម្ម ឬចលនទ្រព្យ ឬអចលនទ្រព្យ ដែលទទួលយក ឬទទួលបាន មានតម្លៃមិនលើសពីបួនរយដុល្លារ ($400) ចំពោះជនណា ដែលមិនមែនជាអ្នកថែទាំ ដែលល្មើសបញ្ញត្តិច្បាប់ ដែលចែងអំពីអំពើចោរកម្ម អំពើកិបកេង អំពើក្លែងឯកសារ ឬអំពើឆបោក ឬដែលល្មើសនឹង Section 530.5 ដែលចែងពីការលួចអត្តសញ្ញាណ ទាក់ទងនឹងព័ត៌មានកំណត់អត្តសញ្ញាណ

កម្មវិធីសេវាគាំពារនៅផ្ទះ (IHSS)
ផ្នែកផ្សេងៗក្នុងក្រមរបស់រដ្ឋ CALIFORNIA

ផ្ទាល់ខ្លួន ឬអត្តសញ្ញាណទ្រព្យ របស់ចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក និងដែលស្គាល់ ឬគួរស្គាល់ជនរងគ្រោះជាចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក។

(e) ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីមិនលើសពីមួយឆ្នាំ ឬពន្ធនាគាររដ្ឋរយៈពេលពីរ បី ឬបួនឆ្នាំ នៅពេលប្រាក់ កម្លាំងពលកម្ម ទំនិញ សេវាកម្ម ឬចលនទ្រព្យ ឬអចលនទ្រព្យ ដែលទទួលយក ឬទទួលបាន មានតម្លៃលើសពីបួនរយដុល្លារ ($400) និងត្រូវពិន័យជាប្រាក់មិនលើសពីមួយពាន់ដុល្លារ ($1,000) ឬផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីមិនលើសពីមួយឆ្នាំ ឬទាំងពិន័យផង និងទាំងទោសជាប់ពន្ធនាគារផង នៅពេលប្រាក់ កម្លាំងពលកម្ម ទំនិញ សេវាកម្ម ឬចលនទ្រព្យ ឬអចលនទ្រព្យ ដែលទទួលយក ឬទទួលបាន មានតម្លៃមិនលើសពីបួនរយដុល្លារ ($400) ចំពោះអ្នកថែទាំចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុកណា ដែលល្មើសបញ្ញត្តិច្បាប់ ដែលចែងអំពីអំពើចោរកម្មអំពើកិបកេង អំពើក្លែងបន្លំ ឬអំពើឆបោក ឬដែលល្មើសនឹង Section 530.5 ដែលចែងពីការលួចអត្តសញ្ញាណ ទាក់ទងនឹងព័ត៌មានកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ឬអត្តសញ្ញាណទ្រព្យ របស់ចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក។

(f) ជនណា ដែលបង្ខាំងចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក ដោយខុសច្បាប់ ដោយប្រើអំពើហិង្សា ការគំរាមកំហែង ការឆបោក ឬការបោកប្រាស់ ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររដ្ឋ រយៈពេលពីរ បី ឬបួនឆ្នាំ។

(g) ពាក្យ “ចាស់ជរា” ដែលប្រើក្នុង Section នេះ សំដៅលើជនណាដែលមានអាយុ 65 ឆ្នាំ ឬលើសនេះ។

(h) ពាក្យ “មនុស្សពេញវ័យក្នុងបន្ទុក” ដែលប្រើក្នុង Section នេះ សំដៅលើ ជនណាដែលមានអាយុពី 18 ទៅ 64 ឆ្នាំ ដែលបញ្ជាក់ហិតផ្នែករាងកាយ ឬផ្លូវចិត្ត ដែលរឹតត្បិតគាត់មិនឲ្យធ្វើសកម្មភាពធម្មតា ឬការពារសិទ្ធិរបស់ខ្លួន ដែលរួមបញ្ចូល ដូចជា ជនដែលពិការរូបកាយ ឬពិការខាងការរីកលូតលាស់ ឬដែលសមត្ថភាពរូបកាយ ឬផ្លូវចិត្ត បានថយចុះ ដោយសារតែអាយុ។ “មនុស្សពេញវ័យក្នុងបន្ទុក” រួមបញ្ចូលជនណា ដែលមានអាយុចន្លោះពី 18 និង 64 ឆ្នាំ ដែលត្រូវបានទទួលឲ្យសម្រាកក្នុងមណ្ឌលសុខភាព 24 ម៉ោង ដែលចែងក្នុង Section 1250, 1250.2 និង 1250.3 នៃក្រមសុខភាព និងសុវត្ថិភាព។

(i) ពាក្យ “អ្នកថែទាំ” ដែលប្រើក្នុង Section នេះ សំដៅលើជនណាដែលថែទាំ ឃុំគ្រង ឬគ្រប់គ្រង ឬដែលកាន់តំណែងគ្រប់គ្រងជាទំនុកចិត្ត

ជាមួយនឹងចាស់ជរា ឬមនុស្សពេញវ័យក្នុងបន្ទុក។

(j) គ្មានប្រការណា ក្នុង Section នេះ បង្ការមិនឲ្យមានការចោទប្រកាន់ ក្រោម Section នេះ និង Section 187 ឬ 12022.7 ឬបញ្ញត្តិផ្សេងទៀតក្នុងច្បាប់។ ប៉ុន្តែ ជនណាក៏ដោយ មិនត្រូវទទួលទោសជាប់ពន្ធនាគារបន្ថែម ទាំងក្រោម (2) និង (3) នៃកថាខណ្ឌ (b) ចំពោះបទល្មើសតែមួយ ឬជនណាក៏ដោយ ក៏មិនត្រូវទទួលទោសជាប់ពន្ធនាគារបន្ថែម ទាំងក្រោម Section 12022.7 និងទាំងក្រោម (2 ) ឬ (3) នៃកថាខណ្ឌ (b) ចំពោះបទល្មើសតែមួយឡើយ។

(k) ក្នុងករណីណាក៏ដោយ ដែលជនណាម្នាក់ ត្រូវបានកាត់ទោស ចំពោះការល្មើសនឹងបញ្ញត្តិទាំងនេះ តុលាការអាចតម្រូវឱ្យគាត់ទទួលការប្រឹក្សាយោបល់ដ៏សមរម្យ ជាលក្ខខណ្ឌសាកល្បង។ ជនជាប់ចោទណា ដែលត្រូវបានបង្គាប់ឱ្យចូលរួមក្នុងកម្មវិធីប្រឹក្សាយោបល់ នឹងទទួលខុសត្រូវបង់ចំណាយចូលរួមរបស់ខ្លួន ក្នុងកម្មវិធីប្រឹក្សាយោបល់ តាមការកំណត់ដោយតុលាការ។ តុលាការត្រូវពិចារណាលើសមត្ថភាពបង់ប្រាក់របស់ជនជាប់ចោទ ហើយគ្មានជនជាប់ចោទណា ត្រូវបដិសេធមិនឲ្យអនុវត្តលក្ខខណ្ឌសាកល្បង ដោយសារតែខ្លួន គ្មានលទ្ធភាពបង់ចំណាយឡើយ។

**Section 290 នៃក្រមព្រហ្មទណ្ឌរដ្ឋ California កថាខណ្ឌ (c)**

(c) ជនខាងក្រោម ត្រូវបានតម្រូវឱ្យចុះឈ្មោះ

ជនណា ដែលចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1944 ត្រូវបានកាត់ទោស ក្នុងតុលាការណាមួយក្នុងរដ្ឋនេះ ឬក្នុងតុលាការរបស់រដ្ឋសហព័ន្ធ ឬតុលាការយោធា ចំពោះការល្មើសនឹង Section 187 ដែលបានប្រព្រឹត្ត ក្នុងអំឡុងពេលប្រព្រឹត្តបទល្មើស ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬរំលោភសេពសន្ថវៈ ឬអំពើណាមួយ ដែលត្រូវផ្តន្ទាទោសក្រោម Section 286, 288, 288a, ឬ 289 ចំពោះការល្មើសនឹង Section 207 ឬ 209 ដែលបានប្រព្រឹត្តដោយមានចេតនារំលោភលើ Section 261, 286, 288, 288a, ឬ 289 ចំពោះការល្មើសនឹង Section 220 លើកលែងតែការវាយប្រហារ ក្នុងគោលបំណងបង្កកាយវិកលកម្ម ចំពោះការលើសនឹង Section 243.4 កថាខណ្ឌ (1), (2), (3), (4) ឬ (6) នៃ (a) ក្នុង Section 261 កថាខ័ណ្ឌ (1) នៃ (a) ក្នុង Section 262 ពាក់ព័ន្ធនឹងការប្រើកម្លាំង ឬហិង្សា ដែលជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររដ្ឋ ចំពោះការល្មើសនឹង Section 264.1, 266, ឬ 266c, (b) នៃ Section 266h, (b) នៃ Section 266i, Section 266j, 267, 269, 285, 286, 288, 288a, 288.3 , 288.4, 288.5, 288.7, 289, ឬ 311.1, (b), (c), ឬ (d) នៃ Section 311.2, Section 311.3, 311.4, 311.10, 311.11 ឬ 647.6, Section 647a មុន, (c) នៃ Section 653f, 1 ឬ 2 នៃ Section 314 ពាក់ព័ន្ធនឹងបទល្មើសអំពើកាមគុណក្រោម Section 272, ឬចំពោះការល្មើសបទឧក្រិដ្ឋលើ Section 288.2 និងចំពោះការល្មើសនឹង ច្បាប់យុត្តិសាស្ត្រមុនៗ ដែលរួមបញ្ចូលធាតុផ្សំទាំងអស់នៃបទល្មើសណាមួយខាងលើ ឬជនណា ដែលចាប់តាំងពីកាលបរិច្ឆេទនោះ ដែលត្រូវបានផ្តន្ទាទោសពីបទប៉ុនប៉ង ឬសមគំនិតប្រព្រឹត្តបទល្មើសណាមួយខាងលើ។

## កម្មវិធីសេវាគាំពារនៅផ្ទះ (IHSS)
## ផ្នែកផ្សេងៗក្នុងក្រមរបស់រដ្ឋ CALIFORNIA

**Section 667.5 នៃក្រមព្រហ្មទណ្ឌរដ្ឋ California កថាខណ្ឌ (c)**

(c) ក្នុងគោលបំណងនៃ Section នេះ “បទឧក្រិដ្ឋហិង្សា” សំដៅលើសកម្មភាពណាមួយ ដូចខាងក្រោម៖

(1) អំពើឃាតកម្ម ឬមនុស្សឃាតដោយមិនបានគិតទុកជាមុន។

(2) អំពើកាយវិកលកម្ម។

(3) អំពើរំលោភសេពសន្ថវៈ ដែលកំណត់និយមន័យក្នុង (2) ឬ (6) នៃ (a) ក្នុង Section 261 ឬ (1) ឬ (4) នៃ (a) ក្នុង Section 262។

(4) អំពើប្រុសរួមភេទដូចគ្នា ដែលកំណត់និយមន័យក្នុង (c) ឬ (d) នៃ Section 286 ។

(5) អំពើរំលោភដោយប្រើមាត់ ដែលកំណត់និយមន័យក្នុង (c) ឬ (d) នៃ Section 288a ។

(6) អំពើកាមគុន ដែលកំណត់និយមន័យ ក្នុង (a) ឬ (b) នៃ Section 288 ។

(7) បទឧក្រិដ្ឋណា ដែលត្រូវផ្តន្ទាទោសប្រហារជីវិត ឬជាប់ពន្ធនាគាររដ្ឋអស់មួយជីវិត។

(8) បទឧក្រិដ្ឋណា ដែលជនជាប់ចោទបង្ករបួសធ្ងន់ធ្ងរខ្លាំងលើជនផ្សេងទៀត លើកលែងតែជាជនសមគំនិត ដែលត្រូវបានចោទ និងបញ្ជាក់ភស្តុតាង ក្រោម Section 12022.7, 12022.8 ឬ 12022.9 នៅ ឬក្រោយថ្ងៃទី 1 ខែកក្កដាឆ្នាំ 1977 ឬដែលកំណត់ជាក់លាក់មុនថ្ងៃទី 1 ខែកក្កដាឆ្នាំ 1977 ក្នុង Section 213, 264, និង 461 ឬបទឧក្រិដ្ឋណា ដែលជនជាប់ចោទប្រើអាវុធ ដែលការប្រើប្រាស់ត្រូវបានចោទ និងបញ្ជាក់ភស្តុតាង ដូចចែងក្នុង (a) នៃ Section 12022.3, ឬ Section 12022.5 ឬ 12022.55។

(9) អំពើប្លន់។

(10) ការដុតបំផ្លាញ ដែលល្មើសនឹង (a) ឬ (b) នៃ Section 451 ។

(11) ការដាក់បញ្ចូលអង្គជាតិ ដែលកំណត់និយមន័យក្នុង (a) ឬ (j) នៃ Section 289 ។

(12) អំពើមនុស្សឃាតកម្មដោយគិតទុកជាមុន។

(13) អំពើល្មើសនឹង Section 12308, 12309, ឬ 12310 ។

(14) ការចាប់ជំរិត។

(15) ការវាយប្រហារ ដោយមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដែលល្មើសនឹង Section 220 ។

(16) ការរំលោភបំពានផ្លូវភេទកុមារជាបន្តបន្ទាប់ ដែលល្មើសនឹង Section 288.5 ។

(17) ការប្លន់រថយន្ត ដែលកំណត់និយមន័យក្នុង (a) នៃ Section 215 ។

(18) ការរំលោភសេពសន្ថវៈ ការរំលោភប្រពន្ធឬប្តី ឬការដាក់បញ្ចូលអង្គជាតិ ដែលល្មើសនឹង Section 264.1 ។

(19) ការជំរិតទារប្រាក់ ដែលកំណត់និយមន័យ ក្នុង Section 518 ដែលបង្កើតជាបទឧក្រិដ្ឋរំលោភលើ Section 186.22 នៃក្រមព្រហ្មទណ្ឌ។

(20) ការគំរាមកំហែងដល់ជនរងគ្រោះ ឬសាក្សី ដែលកំណត់និយមន័យក្នុង Section 136.1 ដែលបង្កើតជាបទឧក្រិដ្ឋរំលោភលើ Section 186.22 នៃក្រមព្រហ្មទណ្ឌ។

(21) អំពើចូលផ្ទះលួចថ្នាក់ទីមួយ ដែលកំណត់និយមន័យ ក្នុង (a) នៃ Section 460 ដែលត្រូវបានចោទ និងបញ្ជាក់ភស្តុតាងថា អ្នកផ្សេងទៀតក្រៅពីអ្នកសមគំនិត មានវត្តមានក្នុងលំនៅដ្ឋាន នៅពេលប្រព្រឹត្តបទល្មើសចូលផ្ទះលួចនេះ។

(22) អំពើល្មើសនឹង Section 12022.53 ។

(23) អំពើល្មើសនឹង (b) ឬ (គ) នៃ Section 11418។ អង្គនីតិបញ្ញត្តិរកឃើញ និងប្រកាសថា បទឧក្រិដ្ឋទាំងនេះ ត្រូវទទួលបានការពិចារណាជាពិសេស នៅពេលផ្តន្ទាទោស ដើម្បីបង្ហាញពីការថ្កោលទោសរបស់សង្គមចំពោះបទឧក្រិដ្ឋហិង្សាប្រឆាំងមនុស្សទាំងនេះ។

**Section 1192.7 នៃក្រមព្រហ្មទណ្ឌរដ្ឋ California កថាខណ្ឌ (c)**

(c) ពាក្យ “បទឧក្រិដ្ឋធ្ងន់ធ្ងរ” សំដៅលើបទល្មើស ដូចខាងក្រោម៖

(1) អំពើឃាតកម្ម ឬមនុស្សឃាតដោយមិនគិតទុកជាមុន; (2) កាយវិកលកម្ម; (3) អំពើរំលោភសេពសន្ថវៈ; (4) អំពើប្រុសរួមភេទដូចគ្នា ដោយប្រើកម្លាំង ហិង្សា ការបង្ខិតបង្ខំ ការកំហែង ការគំរាមបង្ករបួសរូបកាយធ្ងន់ធ្ងរ ឬការភ័យខ្លាចនឹងទទួលរងរបួសរូបកាយជាបន្ទាន់ និងខុសច្បាប់មកលើជនរងគ្រោះ ឬបុគ្គលផ្សេងទៀត; (5) ការរំលោភដោយប្រើមាត់ ដោយប្រើកម្លាំង ហិង្សា ការបង្ខិតបង្ខំ ការកំហែង ការគំរាមបង្ករបួសរូបកាយធ្ងន់ធ្ងរ ឬការភ័យខ្លាចនឹងទទួលរងរបួសរូបកាយជាបន្ទាន់ និងខុសច្បាប់ មកលើជនរងគ្រោះ ឬបុគ្គលផ្សេងទៀត; (6) អំពើកាមគុនមកលើកុមារអាយុក្រោម 14 ឆ្នាំ; (7) បទឧក្រិដ្ឋណា ដែលត្រូវផ្តន្ទាទោសប្រហារជីវិត ឬឲ្យជាប់ពន្ធនាគាររដ្ឋអស់មួយជីវិត; (8) បទឧក្រិដ្ឋណា ដែលជនជាប់ចោទបង្ករបួសធ្ងន់ធ្ងរដោយផ្ទាល់មកលើជនណាម្នាក់ ក្រៅពីជនសមគំនិត ឬបទឧក្រិដ្ឋ ដែលជនជាប់ចោទប្រើអាវុធដោយផ្ទាល់; (9) បទមនុស្សឃាតដោយគិត

ទុកជាមុន; (10) ការវាយប្រហារ ដោយមានចេតនាប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ឬអំពើប្លន់; (11) ការវាយប្រហារដោយមានអាវុធ ឬឧបករណ៍ប្រល័យជីវិតមកលើមន្ត្រីរក្សាសន្តិភាព; (12) ការវាយប្រហារពីសំណាក់អ្នកជាប់ទោសមួយជីវិត មកលើជនដែលមិនជាប់



ទោសក្នុងពន្ធនាគារ; (13) ការវាយប្រហារដែលប្រើអាវុធប្រល័យជីវិតដោយអ្នកទោស; (14) អំពើដុតបំផ្លាញ; (15) ការបន្ទុះឧបករណ៍បំផ្ទុះបំផ្លាញ ឬគ្រាប់ផ្ទុះណា ដោយមានចេតនាបង្ករបួស; 16) ការបន្ទុះឧបករណ៍បំផ្ទុះបំផ្លាញ ឬគ្រាប់ផ្ទុះ ដែលបង្ករបួសរូបកាយ របួសរូបកាយធ្ងន់ធ្ងរ ឬកាយវិកលកម្ម; (17) ការបន្ទុះឧបករណ៍បំផ្ទុះបំផ្លាញ ឬគ្រាប់ផ្ទុះ ដោយមានចេតនាសម្លាប់មនុស្ស; (18) អំពើចូលផ្ទះលួចថ្នាក់ទីមួយ; (19) អំពើប្លន់ ឬអំពើប្លន់ធនាគារ; (20) អំពើចាប់ជំរិត; (21) អំពើចាប់ចំណាប់ខ្មាំងដោយអ្នកជាប់ទោសក្នុងពន្ធនាគាររបស់រដ្ឋ; (22) ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ដែលផ្តន្ទាទោសប្រហារជីវិត ឬជាប់ពន្ធនាគាររបស់រដ្ឋអស់មួយជីវិត; (23) បទឧក្រិដ្ឋណា ដែលជនជាប់ចោទបានប្រើអាវុធគ្រោះថ្នាក់ ឬប្រល័យជីវិតដោយផ្ទាល់; (24) ការលក់ ការផ្គត់ផ្គង់ ការផ្តល់ឲ្យ ការប្រគល់ ឬការស្នើលក់ ផ្គត់ផ្គង់ ផ្តល់ឲ្យ ប្រគល់ថ្នាំហេរ៉ូអ៊ីន ថ្នាំកូកាអ៊ីន ថ្នាំ phencyclidine (PCP) ឬថ្នាំទាក់ទងនឹងមេតំហ្វេតាមីន ដែលរៀបរាប់នៅក្នុងកថាខណ្ឌ (2) នៃ (d) ក្នុង Section 11055 ឬ នៃក្រមសុខភាព និងសុវត្ថិភាព ឬសារធាតុផលិតមេតំហ្វេតាមីន ដែលរៀបរាប់ក្នុង (a) នៃកថាខណ្ឌ (1) នៃ (f) ក្នុង Section 11055 ឬ (a) នៃ Section 11100 នៃក្រមសុខភាព និងសុវត្ថិភាព; (25) អំពើល្មើសនឹង (a) នៃ Section 289 ដែលសម្រេចអំពើនេះផ្ទុយនឹងឆន្ទៈរបស់ជនរងគ្រោះ ដោយប្រើកម្លាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការភ័យខ្លាចរងរបួសភ្លាមៗ និងខុសច្បាប់មកលើជនរងគ្រោះ ឬអ្នកផ្សេងទៀត; (26) អំពើចោរកម្មធំៗ ដែលប្រើកាំភ្លើង; (27) អំពើប្លន់រថយន្ត; (28) បទឧក្រិដ្ឋណា ដែលជាបទឧក្រិដ្ឋរំលោភលើ Section 186,22; (29) ការវាយប្រហារ ដោយមានចេតនាប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ប្រុសរួមភេទដូចគ្នា ឬអំពើរំលោភដោយប្រើមាត់ ដែលបំពានលើ Section 220; (30) ការជះទឹកអាស៊ីត ឬសារធាតុឆេះ ដែលរំលោភលើ Section 244; (31) ការវាយប្រហារដោយប្រើអាវុធប្រល័យជីវិត កាំភ្លើង កាំភ្លើងយន្ត អាវុធវាយប្រហារ ឬកាំភ្លើងស្វ័យប្រវត្តិ ឬការវាយប្រហារមកលើ មន្ត្រីរក្សាសន្តិភាព ឬមន្ត្រីពន្លត់អគ្គិភ័យ ដែលបំពានលើ Section 245; (32) ការវាយប្រហារដោយប្រើអាវុធមកលើបុគ្គលិកនៃសេវាដឹកជញ្ជូនសាធារណៈ មន្ត្រីឃុំគ្រង ឬបុគ្គលិកសាលារៀន ដែលល្មើសនឹង Section 245.2, 245.3 ឬ 245.5; (33) ការបាញ់កាំភ្លើងនៅផ្ទះ រថយន្ត ឬយន្តហោះដែលមានមនុស្ស ដែលល្មើសនឹង Section 246; (34) ការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ឬដាក់បញ្ចូលអង្គជាតិ ដោយសហការជាមួយនឹងជនម្នាក់ផ្សេងទៀត ដែលល្មើសនឹង Section 264.1; (35) ការបំពានផ្លូវភេទកុមារជាបន្តបន្ទាប់ ដែលល្មើសនឹង Section 288,5; (36) ការបាញ់ប្រហារចេញពីរថយន្ត ដែលល្មើសនឹង (c) ឬ (d) ក្នុង Section 12034; (37) ការបំភិតបំភ័យជនរងគ្រោះ ឬសាក្សី ដែលល្មើសនឹង Section 136,1; (38) បទល្មើស គំរាមកំហែង ដែលល្មើសនឹង Section 422; (39) ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ដែលចែងក្នុងកថាខណ្ឌនេះ លើកលែងតែការវាយប្រហារ; (40) ការល្មើសនឹង Section 12022.53; (41) ការល្មើស (b) ឬ (c) ក្នុង Section 11418; និង (42) ការឃុបឃិតប្រព្រឹត្តបទល្មើស ដែលបានរៀបរាប់ ក្នុងកថាខណ្ឌនេះ។

**Section 10980 នៃក្រមសុខាមាលភាព និងស្ថាប័នរបស់រដ្ឋ California កថាខណ្ឌ (2) នៃ (c) និង (g)**

(c) នៅពេលណា ដែលជនណាម្នាក់ បានទទួល ឬរក្សាទុកនូវជំនួយ ក្រោមបញ្ញត្តិនៃប្រការនេះ ដើម្បីខ្លួនឯង ឬកុមារ ដែលគ្មានសិទ្ធិទទួល ដោយមានចេតនា និងបំណងបោកប្រាស់ តាមរយៈការធ្វើសេចក្តីថ្លែង ឬការអះអាងមិនពិត ឬការមិនបង្ហាញការពិត ឬការក្លែងបន្លំខ្លួនជាអ្នកផ្សេង ឬតាមរយៈឧបករណ៍ក្លែងបន្លំដទៃទៀត ជននោះត្រូវផ្តន្ទាទោស ដូចខាងក្រោមៈ

(2) ត្រូវផ្តន្ទាទោសឲ្យជាប់ក្នុងពន្ធនាគាររបស់រដ្ឋរយៈពេល 16 ខែ ពីរឆ្នាំ ឬបីឆ្នាំ ត្រូវពិន័យជាប្រាក់មិនលើសពីប្រាំពាន់ដុល្លារ ($ 5,000) ឬត្រូវជាប់ពន្ធនាគារផង និងពិន័យជាប្រាក់ផង; ឬត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីរយៈពេលមិនលើសពីមួយឆ្នាំ ត្រូវពិន័យជាប្រាក់ ដែលមិនលើសពីមួយពាន់ដុល្លារ ($1,000) ឬត្រូវជាប់ពន្ធនាគារផង និងពិន័យជាប្រាក់ផង ប្រសិនបើជំនួយ ដែលបានទទួល ឬរក្សាទុកនោះ មានចំនួនលើសពីប្រាំបួនរយហាសិបដុល្លារ ($950)។

(g) ជនណាដែលមានចេតនាប្រើប្រាស់ ផ្ទេរ លក់ ទិញ ឬកាន់កាប់ប័ណ្ណអាហារ អត្ថប្រយោជន៍ដែលផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក ឬការអនុញ្ញាតឲ្យចូលរួមក្នុងកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែមរបស់រដ្ឋសហព័ន្ធ តាមរបៀបដែលមិនអនុញ្ញាត ក្នុងជំពូកទី 10 (ចាប់ពី Section 18900) នៃPart 6 ឬដោយច្បាប់ស្តីពីប័ណ្ណអាហាររបស់រដ្ឋសហព័ន្ធ ឆ្នាំ 1977 (ច្បាប់សាធារណៈ 95–113 និងរាល់វិសោធនកម្មទាំងអស់) ឬច្បាប់អាហារ និងអាហារូបត្ថម្ភ ឆ្នាំ 2008 (7 U.S.C. Sec. 2011 et seq.)។

(2) ត្រូវមានពិរុទ្ធពីបទឧក្រិដ្ឋ ប្រសិនបើតម្លៃប័ណ្ណអាហារ ឬការអនុញ្ញាតឲ្យចូលរួមក្នុងកម្មវិធី មានតម្លៃលើសពីប្រាំបួនរយហាសិបដុល្លារ ($950) ហើយត្រូវផ្តន្ទាទោសឲ្យជាប់ក្នុងពន្ធនាគាររបស់រដ្ឋរយៈពេល 16 ខែ ពីរឆ្នាំ ឬបីឆ្នាំ ត្រូវពិន័យជាប្រាក់មិនលើសពីប្រាំពាន់ដុល្លារ ($ 5,000) ឬត្រូវជាប់ពន្ធនាគារផង និងពិន័យជាប្រាក់ផង ឬត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារខោនធីរយៈពេលមិនលើសពីមួយឆ្នាំ ឬត្រូវពិន័យជាប្រាក់ ដែលមិនលើសពីមួយពាន់ដុល្លារ ($1,000) ឬត្រូវជាប់ពន្ធនាគារផង និងពិន័យជាប្រាក់ផង។